Embassy
of the Federal Republic of Germany
Phnom Penh

អនុវត្តដោយ:

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២៤ខែមិថុនា ឆ្នាំ២០២០

**ប្រទេសអូស្ត្រាលី និងប្រទេសអាល្លឺម៉ង់ជួយគាំទ្រកម្មវិធីជាប្រវត្តិសាស្ត្រនៃការផ្ទេរសាច់ប្រាក់ដល់គ្រួសារក្រីក្រ**

ប្រទេសអូស្ត្រាលី និងប្រទេសអាល្លឺម៉ង់មានសេចក្តីសោមនស្សរីករាយ ក្នុងការជួយគាំទ្រកម្មវិធីផ្ទេរសាច់ប្រាក់ជាបន្ទាន់របស់រាជរដ្ឋាភិបាលកម្ពុជា ដល់គ្រួសារក្រីក្រក្នុងអំឡុងពេលនៃជំងឺកូវីដ ១៩។

ប្រទេសអូស្ត្រាលី និងប្រទេសអាល្លឺម៉ង់មើលឃើញពីគំនិតផ្តួចផ្តើមនេះ ជាទិវាប្រវត្តិសាស្ត្រមួយរបស់ប្រទេសកម្ពុជា ដែលត្រូវបានប្រកាសឲ្យអនុវត្តនាថ្ងៃនេះដោយ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា។ ពួកយើងមានមោទនភាពចំពោះជំនួយដ៏យូរអង្វែងរបស់យើងមកលើកម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្ររបស់ក្រសួងផែនការ ដែលផ្តល់លទ្ធភាពក្នុងការអនុវត្តន៍គំនិតផ្តួចផ្តើមដ៏មានសារៈសំខាន់នេះ។

កម្មវិធីផ្ទេរសាច់ប្រាក់ដ៏ធំលើកដំបូងរបស់កម្ពុជា អាចលេចជារូបរាងឡើងដោយសារតែកម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ ប្រទេសអូស្ត្រាលី (ផ្តល់ជំនួយចំនួន១៤លានដុល្លាអូស្ត្រាលី) និងប្រទេសអាល្លឺម៉ង់(ផ្តល់ជំនួយចំនួន៦,១លានអឺរ៉ូ) បាននិងកំពុងធ្វើការជាមួយក្រសួងផែនការ តាម រយៈទីភ្នាក់ងារកិច្ចសហប្រតិបត្តការអាល្លឺម៉ង់*(GIZ)* អស់រយៈពេលជាង១០ឆ្នាំ ក្នុងការបង្កើត និងថែរក្សាប្រព័ន្ធពិសេសរបស់កម្ពុជា មួយនេះ ក្នុងការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ។

ប្រព័ន្ធទិន្នន័យនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ហើយបច្ចុប្បន្ននេះមានគ្រួសារចំនួន៥៦០.០០០ គ្រួសារ(ស្មើនឹងប្រជាជនកម្ពុជា២,៣លាននាក់) ទទួលបានសិទ្ធិចូលរួមក្នុងកម្មវិធីថ្មីក្នុងការទទួលបានសាច់ប្រាក់នេះ។

ឯកឧត្តម*Pablo Kang* ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជាបានមានប្រសាសន៍ថា "ក្នុងនាមជាប្រទេសជិតខាង និងជាមិត្តភ័ក្តជាមួយប្រជាជនកម្ពុជា ប្រទេសអូស្ត្រាលីមានចំណែករួមមួយលើភាពស៊ាំសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា និងមានឆន្ទៈមុតមាំក្នុងការធ្វើការជាមួយដៃគូនានា ដើម្បីបង្កើតវិថីដែលអាចដំណើរការបានក្នុងការអភិវឌ្ឍន៍ជីវភាពពលរដ្ឋកម្ពុជាគ្រប់រូបឲ្យកាន់តែល្អប្រសើរ ។"

ឯកអគ្គរាជទូត *Kang* បានបន្តថា "យើងខ្ញុំសូមអបអរសាទរដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រើប្រាស់ប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រនេះ ដែលប្រទេសអូស្ត្រាលីបាននិងកំពុងជួយបង្កើតឡើងអស់រយៈពេលជាងមួយទស្សវត្សកន្លងទៅ ក្នុងគោលបំណងធ្វើឲ្យការផ្ទេរសាច់ប្រាក់បានទៅដល់អ្នកដែលកំពុងមានតម្រូវការជាងគេបំផុត។ "

លោកបណ្ឌិត *Günter Riethmacher* នាយកទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា "ក្រោមកិច្ចប្រឹងប្រែងរួមជាមួយដៃគូកម្ពុជា យើងអាចសម្រេចបាននូវការបន្ថែមគ្រួសារថ្មីចំនួន ៥០.០០០គ្រួសារទៅក្នុងប្រព័ន្ធទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្នុងខែនេះ ដោយប្រើប្រាស់ប្រព័ន្ធថ្មីមួយ ហៅថា*កម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើរសុំ* ដែលផ្តល់ឪកាសដល់គ្រួសារនានាទទួលបានការកំណត់អត្តសញ្ញាណនិងបញ្ចូលឈ្មោះទៅក្នុងប្រព័ន្ធទិន្នន័យពេញមួយឆ្នាំដោយមិនចាំបាច់រង់ចាំការធ្វើបច្ចុប្បន្នភាពតាមពេលវេលាកំណត់។ "លោកបណ្ឌិត *Riethmacher* មានប្រសាសន៍បន្ថែមថា "កម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រតាមការស្នើរសុំ នឹងបន្តជានិរន្ត ជាផ្នែកមួយនៃកម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ។ "

ឯកឧត្តម *Christian Berger*ឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ប្រចាំប្រទេសកម្ពុជា បានមានប្រសាសន៍ថា "កម្ពុជាបាននិងកំពុងគ្រប់គ្រងវិបត្តិសុខភាពប្រកបដោយជោគជ័យ ហើយបច្ចុប្បន្ននេះកំពុងតែដោះស្រាយផលប៉ះពាល់សេដ្ឋកិច្ច-សង្គម ដោយសារវិបត្តិនេះ។ កម្មវិធីផ្ទេរសាច់ប្រាក់ដែលបានគ្រោងទុកនេះ គឺជាយន្តការដ៏មានប្រសិទ្ធិភាពមួយ៖ កម្មវិធីនេះសំដៅជួយគ្រួសារណាដែលកំពុងមានតម្រូវការ ហើយនៅពេលជាមួយគ្នានេះដែរ វាជួយបង្កើនចំណាយក្នុងការប្រើប្រាស់ ដែល

ជួយដល់សេដ្ឋកិច្ចទាំងមូល។ ខ្ញុំមានមោទនភាពដែលតាមរយៈជំនួយពីប្រទេសអាល្លឺម៉ង់ និងប្រទេសអូស្ត្រាលី រាជរដ្ឋាភិបាលកម្ពុជាឥឡូវនេះមានប្រព័ន្ធមួយក្នុងដៃ ក្នុងការជួយដោយផ្ទាល់ដល់ពលរដ្ឋក្រីក្រ និងងាយរងគ្រោះ។ ″

ប្រទេសអូស្ត្រាលី និងប្រទេសអាល្លឺម៉ង់មានការប្តេជ្ញាចិត្តក្នុងការបន្តធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល និងវិស័យឯកជន សម្រាប់ប្រព័ន្ធគាំពារសង្គមដែលជួយគាំទ្រដល់សហគមន៍ឲ្យកាន់តែមានភាពស៊ាំ ហើយពេលនោះពលរដ្ឋគ្រប់រូបនឹងអាចចូលរួមក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម។

***សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង៖***


Australian Embassy: Australian.Embassy.Cambodia@dfat.gov.au

German Embassy: pr-11@phno.diplo.de

GIZ Cambodia: ole.doetinchem@giz.de




***រូបថតទី១៖*** ឯកឧត្តម ***Pablo Kang*** អគ្គរាជទូតអូស្ត្រាលីប្រចាំប្រទេសកម្ពុជា និងលោក Benjamin Knödler, អនុប្រធានបេសកកម្មស្ថានទូតអាល្លឺម៉ង់ អង្កេតមើលដំណើរការសំភាសតាមការស្នើសុំចំពោះអ្នកទទួលផលប្រកបដោយសក្តានុពលម្នាក់ ដោយសមាជិកក្រុមតំណាងភូមិនៅខេត្តព្រៃវែង។
***រូបថតផ្តល់ដោយ៖*** GIZ/Conor Wall



***រូបថតទី២៖*** អ្នកម្តាយមេម៉ាយម្នាក់ *(single mother)* និងកូនប្រុសរបស់គាត់កាន់បណ្ណសមធម៌នៅរាជធានីភ្នំពេញ។

***រូបថតផ្តល់ដោយ៖*** GIZ/Conor Wall